# ***ការផ្លាស់ប្តូរចំពោះការមកទទួលយកកញ្ចប់សិក្សា***
***ចាប់ផ្តើមនៅថ្ងៃទី១០ ខែ សីហា***

*ជំរាបមាតាបិតា/អាណាព្យាបាល,*

*យោងទៅលើសេចក្តីប្រកាសពីរដ្ឋាភិបាលអំពីការរឹតបន្តឹង,យើងខ្ញុំត្រូវធ្វើការផ្លាស់ប្តូរខ្លះចំពោះកញ្ចប់សិក្សាសំរាប់រយៈពេលរហូតដល់ចុងត្រីមាសទី៣។បើលោកអ្នករស់នៅក្រៅរង្វង់៥គីឡូម៉ែត្រពីសាលាហើយបើប្រាថ្នាមកយកកញ្ចប់សិក្សាទៅផ្ទះឲ្យកុមាររៀន,សូមប្រាប់ឲ្យសាលាដឹងថាតើលោកអ្នកយកតាមរបៀបណា។*
*ចំពោះការរៀនពីចម្ងាយ,កញ្ចប់សិក្សាសំរាប់កុមារពីថ្នាក់មូលដ្ឋានដល់ថ្នាក់ទី៤នឹងទុកឲ្យមាតាបិតាមកយកក្នុងរយៈពេលពីរសប្តាហ៏ម្តងតាមថ្ងៃខែដូចបានរាយនៅខាងក្រោម។ចំពោះកញ្ចប់សិក្សាសំរាប់ថ្នាក់ទី៥និងទី៦,កុមារអាចចូលទៅយកតាមរយៈអ៊ិនធើណែត,ម្ប៉ោះហើយកុមារមិនចាំបាច់មកសាលាឡើយ។*

***ការរៀបចំចាត់ចែងជាថ្មីមានដូចតទៅ:***

***<u>ថ្ងៃច័ន្ទ ទី១០/៨</u>****-ថ្នាក់មូលដ្ឋានដល់ថ្នាក់ទី៤:-មកយកកញ្ចប់ថ្មី-ប្រគល់កិច្ចការធ្វើរួចឲ្យគ្រូ-ថ្នាក់ទី៥/៦-យកតាមរយៈអ៊ិនធើណែត*
***<u>ថ្ងៃច័ន្ទ ទី២៤/៨</u>****-ថ្នាក់មូលដ្ឋានដល់ទី៤:មកយកកញ្ចប់ថ្មី-ប្រគល់កិច្ចការធ្វើរួចឲ្យគ្រូ-ថ្នាក់ទី៥/៦-យកតាមរយៈអ៊ិនធើណែត*
***<u>ថ្ងៃច័ន្ទ ទី០៧/៩</u>****-ថ្នាក់មូលដ្ឋានដល់ទី៤:មកយកកញ្ចប់ថ្មី-ប្រគល់កិច្ចការធ្វើរួចឲ្យគ្រូ-ថ្នាក់ទី៥/៦-យកតាមរយៈអ៊ិនធើណែត*

*ការចាត់ចែងសំរាប់មកយកកញ្ចប់សិក្សានិងប្រគល់កិច្ចការដែលបានធ្វើរួចមានដូចតទៅ:*
*ដើម្បីកាត់បន្ថយចំនួនមនុស្សធំមកសាលា,យើងបានបែងចែកពេលវេលាដោយយោងទៅតាមនាមត្រកូលរបស់គ្រួសារ។បុគ្គលិកសាលានឹងជួយមើលការខុសត្រូវដើម្បីធ្វើឲ្យដំណើរការបានល្អ។សូមកុំភ្លេចឈរឃ្លាតឆ្ងាយពីគ្នានៅរាល់ពេល។*

*ពីម៉ោង៩:៣០ព្រឹកដល់ម៉ោង១១:០០ព្រឹក,គ្រួសារមាននាមត្រកូលពី* A –M
*មកយកកញ្ចប់សិក្សាទៅផ្ទះពីម៉ោង១១:០០ព្រឹកដល់ម៉ោង១២:៣០ថ្ងៃត្រង់, គ្រួសារមាននាមត្រកូលពី* N –Z

***កន្លែងមកទទួលដូចតទៅ:***

*សាខាវ៉ាល្លី* (Valley Campus): *ផ្លូវដើរច្រកទ្វារខាងមុខ*
*សាខាខាងលិច*(WestCampus*:* *បន្ទប់ធំនៅចុងទីចតឡានសំរាប់បុគ្គលិកសាលា*
*ប្រសិនជាលោកអ្នកមិនអាចមកយកកញ្ចប់សិក្សាក្នុងថ្ងៃដូចបានជំរាបនៅខាងលើនោះទេ,សូមទាក់ទងនឹងការិយាល័យដើម្បីមកយកនៅថ្ងៃក្រោយ។*

*សាខាវ៉ាល្លី :* Valley Campus*:* *៩៥៤៧ ៣២២២*
*សាខាខាងលិច* :West Campus: *៩៥៨៦ ៦៤០*

*សូមអរគុណ*

Juliie Fisher
*នាយកសាលា*